# ៩~រឿង ចៅផ្កាប់ត្រឡោក

កាលពីព្រេងនាយមានសេដ្ឋីប្ដីប្រពន្ធមានកូនក្រមុំមួយនាក់រូបឆោមល្អណាស់ ។ ពួកកម្លោះៗ ជាច្រើនស្ម័គ្រចិត្តស្រឡាញ់ បានប្រាប់មាតាបិតាអោយទៅដណ្ដឹងកូនក្រមុំមហាសេដ្ឋី ៗ នោះក៏ព្រមអោយឥតប្រកែក តែមានធ្វើខសន្យាថា "បើកម្លោះឈ្មោះណាចង់បានត្រូវសង់ផ្ទះ៥ល្វែងតែមួយថ្ងៃអោយហើយ បើធ្វើមិនហើយ សេដ្ឋីនោះផ្ដាច់មិនអោយកូនក្រមុំទេ" ។ កម្លោះដទៃខូចខាតជំនូនជាច្រើននាក់ដោយធ្វើផ្ទះមួយថ្ងៃមិនហើយសេដ្ឋីក៏ផ្ដាច់មិនអោយកូនក្រមុំ ។ ខណៈនោះមានកម្លោះម្នាក់ជាអ្នកមានគំនិតមានឧបាយកលប្រាជ្ញា ឈ្មោះថា "ចៅផ្កាប់ត្រឡោក" ជាកូនអ្នកមានគ្រាន់បើបានសុំប្រាក់មាតាបិតាយកទៅទិញឈើលបធ្វើផ្ទះ ប្រុងប្រៀបគ្រប់ប្រដាប់ជាស្រេច រួចកោសរូសខាត់ត្រឡោកស្អាត ហើយប្រាប់មាតាបិតាឲ្យទៅដណ្ដឹងកូនក្រមុំមហាសេដ្ឋីនោះ ។ ឯមាតាបិតាក៏ទិញផ្លែឈើមើមឈើបានច្រើនតុ ហើយពឹងញាតិសន្ដាន អោយជួយកាន់ជំនូននោះទៅដល់ផ្ទះមហាសេដ្ឋី លើកដៃជម្រាបថា "ខ្ញុំបាទនាងខ្ញុំមកសូមដណ្ដឹងកូនក្រមុំលោក ផ្សំផ្គុំនឹងកូនប្រុសកម្លោះខ្ញុំបាទនាងខ្ញុំ ទោះបីខុសត្រូវសូមលោកមហាសេដ្ឋីអភ័យទោស សូមអោយបានជាសាច់សន្ដានស្ពានមេត្រីតរៀងទៅ" ។

សេដ្ឋីទាំងប្ដីប្រពន្ធស្ដាប់ហើយ ឆ្លើយថា "យើងឥតប្រកែកថាអ្វីទេអ្នក! តែថាថ្ងៃស្អែកនេះអ្នកធ្វើផ្ទះ ៥ល្វែងអោយហើយស្រេចបើធ្វើមិនហើយយើងនឹងផ្ដាច់មិនអោយកូនក្រមុំទេ" ។ មាតាបិតាចៅផ្កាប់ត្រឡោកឮហើយជម្រាបថា "បើកូនខ្ញុំធ្វើផ្ទះថ្ងៃស្អែកនេះមិនហើយស្រេចទេ សូមលោកសេដ្ឋីផ្ដាច់កូនក្រមុំលោកចុះជំនូនប៉ុន្មានតុនេះខ្ញុំបាទនាងខ្ញុំក៏សុខចិត្តជូនលោកទាំងអស់ ឥតគិតយកថ្លៃពីលោកឡើយ" ហើយជូនជំនូនទាំងអស់ទៅសេដ្ឋីៗ ក៏អោយខ្ញុំកំដរលើកផ្ទេរទុកពេញមួយល្វែងផ្ទះហើយយកសម្បកតុថាសមកអោយវិញ ។ មាតាបិតាចៅផ្កាប់ត្រឡោកទទួលតុថាសគ្រប់ចំនួនហើយក៏សំពះលាមហាសេដ្ឋីនាំគ្នាត្រឡប់មកផ្ទះវិញ ។

ក្រោយនោះមហាសេដ្ឋីនឹងភរិយានាំគ្នាទៅមើលជំនួននៅលើផ្ទះនោះ សុទ្ធតែផ្លែឈើមានតម្លៃប្លែកៗពីប្រទេសឆ្ងាយខ្លះ នៅស្រុកអាយខ្លះ សេដ្ឋីក៏ញញឹមញញាក់មុខដាក់ប្រពន្ធថា "ជំនួននេះយើងមុខជាបានស៊ីទទេទៀតហើយ" ។

ចំណែកមាតាបិតាចៅផ្កាប់ត្រឡោកទៅដល់ផ្ទះក៏និយាយប្រាប់កូនថា "សេដ្ឋីព្រមអោយហើយតែគេថាអោយធ្វើផ្ទះតែក្នុងថ្ងៃស្អែកនេះ អោយហើយស្រេច" ។ ចៅផ្កាប់ត្រឡោកឮមាតាបិតាប្រាប់ដូច្នោះ មានចិត្តត្រេកអរណាស់ជម្រាបមាតាបិតាថា "លោកម៉ែលោកឪកុំព្រួយបារម្ភមុខជាបានដូចគំនិតដែលកូនគិតទុកពីថ្ងៃមុន" ហើយចៅផ្កាប់ត្រឡោក ក៏ទៅនិយាយបងប្អូនអ្នកចេះការជាងផ្ទះបានគ្នាច្រើនអោយគេជួយសង់ផ្ទះតែថ្ងៃស្អែកនេះអោយហើយ ។ បងប្អូនគេជួយទាំងអស់គ្នាហើយចៅផ្កាប់ត្រឡោកត្រឡប់មកផ្ទះស្លៀកពាក់តែងខ្លួនស្អាតបាត ពឹងកម្លោះផងគ្នាអោយជូនទៅផ្ទះសេដ្ឋីនោះ លុះឡើងទៅដល់លើផ្ទះសេដ្ឋីសួរថា "ចៅឯងមកមានការអ្វី ?" ។ ចៅផ្កាប់ត្រឡោកលុតជង្គង់ប្រណម្យជម្រាបថា "ម៉ែឪខ្ញុំបាទប្រើខ្ញុំបាទជាកូនអោយមកសូមក្រាបប្រណិប័តន៍លោកឪពុកលោកម្ដាយសូមប្រទានប្រាប់ទីកន្លែងត្រង់ណាអោយទានខ្ញុំបាទ នឹងសង់ផ្ទះខ្ញុំបាននឹងអាលទៅចាត់ការធ្វើក្រែងមិនហើយជូនលោកឪពុកលោកម្ដាយក្នុងវេលាថ្ងៃស្អែកនេះ" ។

សេដ្ឋីទាំងប្ដីប្រពន្ធគន់មើលរូបឬកពាចៅផ្កាប់ត្រឡោក នឹកសរសើរក្នុងចិត្តថា "កូនប្រសាអញគ្រាន់បើដែរតែមុខជាខូចខាតជំនួនដូចអ្នកមុនៗទៀតហើយ" ។ សេដ្ឋីប្រាប់ទីកន្លែងអោយសង់នៅខាងជើងឆ្ងាយពីផ្ទះធំ ចំនួន៥ព្យាម ។

ចៅផ្កាប់ត្រឡោកបានឮសេដ្ឋីប្រាប់ហើយ ក៏ក្រាបសំពះលានាំគ្នាត្រឡប់ទៅផ្ទះវិញ លុះទៅដល់ប្រមូលបងប្អូនជួបជុំយកគ្រឿងផ្ទះដែលធ្ងន់ៗ ផ្ករទេះស្រេចពីយប់របស់ណាល្មមលីសែង ក៏ចាត់ចែងផ្លូវផ្គងដាក់មុខគ្នាជាស្រេច ។ លុះព្រឹកឡើងខ្លះដឹកនឹងរទេះ ខ្លះលីសែងទៅដល់ផ្ទះសេដ្ឋី ខ្លះកាប់ដី ខ្លះជីករណ្ដៅសសរតាមខ្នាតទំហំផ្ទះ៥ល្វែង ខំធ្វើស្រុះគ្នាមិនឈប់ ឈប់តែពេលបរិភោគបាយ បរិភោគបាយរួចនាំគ្នាធ្វើទៀតទាល់តែហើយស្រេចក្នុងវេលាថ្ងៃនោះ រួចចៅផ្កាប់ត្រឡោកឡើងទៅលុតជង្គង់សំពះជូនផ្ទះមហាសេដ្ឋីជាមាតាបិតាក្មេក ហើយនាំគ្នាត្រឡប់ទៅផ្ទះវិញ ។

លុះដល់ថ្ងៃខែបានឫក្សល្អមាតាបិតាទាំងពីរខាង ក៏រៀបវិវាហមង្គលការកូនរួចស្រេច ។ ឯចៅផ្កាប់ត្រឡោកលាក់ត្រឡោកនោះមិនអោយនរណាឃើញសោះដល់ពេលយប់រៀបសែនផ្សំដំណេករួចហើយក៏ដេកក្នុងផ្ទះជាមួយគ្នា ។ ចៅផ្កាប់ត្រឡោកយកត្រឡោកនោះទៅផ្កាប់គ្របពីលើថ្ងាស រួចស្លៀកសំពត់ចងក្បិនប្រយ័ត្នមិនឲ្យត្រឡោកធ្លាក់បាន ហើយដេកឃ្លាតពីភរិយា ធ្វើសម្ងំមិនបានពាល់ដល់ចុងដៃជើងភរិយានោះឡើយ ប្រើឧបាយយ៉ាងនេះ អត់ធន់បាន៣យប់ៗក្រោយទៀត នាងភរិយានោះរសាប់រសល់ខ្វល់ចិត្ត គិតសង្ស័យថា "ប្ដីអញនេះដេកជាមួយគ្នាយូរយប់ហើយ គាត់ធ្វើព្រងើយកន្តើយ ហាក់ដូចជាគ្មានត្រូវការនឹងអញសោះ ឬជាគាត់ខ្ទើយ ឬក្ស័យលិង្គ" គិតក្នុងចិត្តដូច្នោះហើយ ក៏ចង់ដឹងប្រថុយលបលូកស្ទាបមើលអោយច្បាស់ ។

ចៅផ្កាប់ត្រឡោកដេកពុំលក់ទេ តែធ្វើជាស្រមុកខុរៗ ។ នាងប្រពន្ធនោះលូកដៃស្ទាបត្រង់ថ្ងាសនោះ ពានទៅលើត្រឡោកផ្កាប់រលីងណិលដកដៃមកវិញ គិតថា "ប្ដីអញនេះនឹងថាខ្ទើយ ឬក្ស័យលិង្គក៏មិនមែនសណ្ឋានហាក់ដូចជាភេទស្រី តែពោះ គ្មានប្រឡាយមុខ គួរអោយឆ្ងល់ណាស់" ។

លុះព្រឹកឡើង ឱ្សបប្រាប់ម្ដាយតាមដំណើរដែលលបស្ទាបប្ដីសព្វគ្រប់ ។ ម្ដាយឮហើយដកដង្ហើមធំថា "ឱកូនអញអើយ! បានប្ដីអីក៏មិនដូចបុរសទាំងពួង" ហើយនឹងបន្ទោសកូនប្រសាប្រុសនោះថា "បើវាគ្មានប្រដាប់ដូចប្រុសទាំងពួងទេហេតុម្ដេចក៏ស្រឡាញ់កូនអញអីម្ល៉េះ!" ។ គិតហើយក៏ប្រាប់សេដ្ឋីជាប្ដីតាមដំណើរកូនស្រីប្រាប់សព្វគ្រប់ ។ សេដ្ឋីស្ដាប់ហើយគិតថា "បើអញនិយាយខ្លាំងខ្មាស់អ្នកជិតខាង" ហើយក៏និយាយខ្សឹបខ្សៀវតែពីរនាក់ប្ដីប្រពន្ធថា "កូនប្រសាយើងនេះវាគ្រាន់បើដែរណ្ហើយគេហ៎អើយ! អាណិតវាអោយប្រាក់ថ្លៃភស្តុភារបណ្ណាការ និងថ្លៃផ្ទះមួយពាន់ប្រាំរយណែនទៅវា ហើយប្រាប់អោយទៅនៅម៉ែឪវាវិញចុះ" គិតព្រមគ្នាហើយហៅកូនប្រសាថា

"ជឯងមកឯនេះ" ចៅផ្កាបត្រឡោកឮសដិសេដ្ឋីឪពុកក្មេកម្ដាយក្មេកហៅខ្លួនហើយ ក ទៅអង្គុយជិតសំពះសេដ្ឋីៗប្រាប់ថា "ឯងហាក់ដូចជាមិនស្រឡាញ់កូនអញសោះ ណ្ហើយ ចុះអញអោយប្រាក់មួយពាន់ប្រាំរយណែន ឯងយកទៅនៅផ្ទះឪពុកម្ដាយឯងវិញចុះ" រួចក៏រាប់ប្រាក់ប្រគល់អោយគ្រប់ចំនួន ។ ចៅផ្កាប់ត្រឡោកទទួលប្រាក់ ហើយជម្រាបថា "លោកឪពុកខ្ញុំបាទសុំហឹបធំ១ ដាក់ប្រាក់ដែលអោយខ្ញុំបាទ ហើយសូមអោយបាវប្រុសៗ ជួយសែងប្រាក់យកទៅអោយដល់ផ្ទះខ្ញុំបាទផង" ។ សេដ្ឋីក៏អោយហឹបដាក់ប្រាក់ ចាត់បាវព្រាវអោយសែងតាមចៅផ្កាប់ត្រឡោកទៅដល់ផ្ទះ ហើយជូនប្រាក់មួយពាន់ប្រាំរយណែននៅក្នុងហឹបទៅមាតាបិតាជម្រាបរឿងសព្វគ្រប់ ក៏ត្រឡប់មកផ្ទះសេដ្ឋីវិញ ។ លុះដល់ហើយចៅផ្កាប់ត្រឡោកធ្វើឫកកិរិយាសញ្ជប់សញ្ជឹង ហាក់ដូចជារលឹកអាល័យសេដ្ឋីនិងភរិយានោះពន់ពេក ។

សេដ្ឋីឃើញហើយសួរថា "ឯង! អញអោយប្រាក់ទៅនៅផ្ទះម៉ែឪឯងវិញហើយ ហេតុម្ដេចក៏មិនទៅ ?" ។

ចៅផ្កាប់ត្រឡោកឆ្លើយជម្រាបសេដ្ឋីថា "ខ្ញុំបាទរលឹកអាល័យលោកម៉ែលោកឪពុក និងនាងជាភរិយាខ្លាំងណាស់ សុំទៅទទួលទានដំណេកតែមួយយប់នេះទៀត ព្រឹកឡើង ខ្ញុំបាទសូមប្រណិប័តន៍លាទៅផ្ទះវិញ" ។

សេដ្ឋីប្ដីប្រពន្ធនិយាយគ្នាថា "យើងអោយវាដេកមួយយប់ទៀតចុះវាមិនទាន់ជាអ្វីទេ ដូចជាដេកជាមួយនឹងប្រុសផងគ្នា" ។ លុះពេលយប់បរិភោគបាយរួចចៅផ្កាប់ត្រឡោកក៏ចូលទៅដេកជាមួយនឹងភរិយា ត្រឡោកនៅផ្កាប់ដដែល ដល់យប់ជ្រៅនាងភរិយាគិតថា "ប្ដីអញទៅនៅផ្ទះគាត់វិញហើយ អញចង់ស្ទាប សង្កេតអោយច្បាស់" ។ ឯចៅផ្កាប់ត្រឡោកដេកផ្ងារដេកពុំលក់ ព្រោះតើតតម្រេកខ្លាំងដូចជាគេខូលត្រឡោក ។ នាងភរិយានោះលូកដៃទៅប៉ះលើត្រឡោកធ្លាក់ឮសូរខ្ទោះ ។ ចៅផ្កាប់ត្រឡោកងាកផាំងចូលទៅរួមរស់នឹងនាងភរិយានោះដោយកំលាំងដ៏ខ្លាំងក្លា ។

លុះព្រឹកឡើង នាងនោះនិយាយជំរាបម្ដាយថា "ម៉ែអើយ បើប្ដីខ្ញុំលាទៅផ្ទះវិញ សូមម៉ែអាណិតកូនឃាត់កុំអោយគាត់ទៅ" ។ មាតាសង្ស័យណាស់សួរកូនៗនិយាយខ្សិបជំរាបមាតាថា "ម៉ែ! ប្ដីខ្ញុំគាត់មានប្រដាប់ដូចប្រុសទាំងពួងមិនមែនជាខ្ទើយទេ" ។

ម្ដាយដឹងចិត្តកូន ក៏ខ្សិបជំរាបប្ដីដោយសម្ងាត់ថា "កូនយើងទាំងពីរវាត្រូវចិត្តគ្នាវាហើយ" ។

សេដ្ឋីឮភរិយានិយាយប្រាប់រឿងកូនសព្វគ្រប់ក៏តបថា "កាលមុនឯងនិយាយប្រាប់អញៗ ក៏ជឿថា ពិតមែន អញបានសងថ្លៃភស្ដុភារបណ្ណាការនិងថ្លៃផ្ទះមួយពាន់ប្រាំរយណែនអោយទៅវា ឥឡូវថាកូនប្រសាយើងមានប្រដាប់ដូចបុរសទាំងពួង ណ្ហើយចុះគេហ៍! បើត្រូវចិត្តគ្នាវាហើយ ប្រាក់ដែលយើងអោយកូនប្រសានោះដូចជាអោយទៅកូនយើងទេ ប្ដីប្រពន្ធវាមានគ្រជាមួយគ្នាចុះ" ហើយសេដ្ឋីក៏ស្ងៀមស្ងាត់រាប់អានកូនតរៀងទៅ ។

លុះដល់សេដ្ឋីប្ដីនិងភរិយាយចាស់ជរាទទួលមរណភាពទៅ វេលាណាស្ដេចក្នុងព្រះនគរនោះទ្រង់ព្រះមេត្តាប្រោស តាំងចៅផ្កាប់ត្រឡោក និង ភរិយាអោយធ្វើជាសេដ្ឋីតាងបិតា លុះអស់ជីវិត ។

**ត្រឡាចម្ដេចមានបណ្ដូល មនុស្សមួយឆាំខមូលណាក៏គ្មានប្រាជ្ញា**